ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
លេខ ០១ ដនស/សជ.

# សារាចរណែនាំ
## អនុវត្តនីតិវិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ

អនុលោមតាមអនុក្រឹត្យលេខ ៤៨អនក្រ.បក. ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សូមធ្វើការណែនាំដូចតទៅ :

**ដំណាក់កាលទី ១ : អំពីការដាក់ពាក្យស្នើសុំចុះបញ្ជីដី :**

អ្នកកាន់កាប់ដីដែលមានបំណងស្នើសុំចុះបញ្ជីក្បាលដីរបស់ខ្លួន (ទោះមានទំហំប៉ុន្មានក្តី) ត្រូវបំពេញពាក្យសុំតាមគំរូដែលបានរៀបចំ ដាក់ជូនរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ តាមរយៈមេឃុំ ចៅសង្កាត់ នៃឃុំ សង្កាត់ដែលក្បាលដី នោះស្ថិតនៅ ។
ពាក្យស្នើសុំត្រូវធ្វើជាពីរច្បាប់ និងអាចមានឯកសារណាមួយផ្សេងៗភ្ជាប់មកជាមួយ ដូចជាឯកសារ និង. ភស្តុតាង ទាក់ទងនឹងក្បាលដី ឬសិទ្ធិលើក្បាលដីដែលស្នើសុំចុះបញ្ជី ។

មេឃុំ ចៅសង្កាត់ ត្រូវពិនិត្យមើលពាក្យស្នើសុំ ណែនាំឱ្យសាមីអ្នកកាន់កាប់ដីបំពេញបានគ្រប់គ្រាន់ តាមខ្លឹមសារដែលបានរៀបចំ ថាតើសេចក្តីដែលសាមីអ្នកស្នើសុំបានបំពេញនោះស្របតាមហេតុការណ៍ដែលបានកើតឡើងជាក់ស្តែង ដែរ ឬទេ ?
ចំណុចដែលត្រូវយកចិត្តទុកដាក់ ជាសំខាន់នោះ គឺលក្ខណៈនៃការចូលកាន់កាប់ដីមានប្រើអំពើហឹង្សា ឬគ្មាន ? កាលបរិច្ឆេទនៃការចូលកាន់កាប់ដី ពិតប្រាកដ ដែរឬទេ ?
ទីតាំងក្បាលដី មានប៉ះពាល់ដល់ទ្រព្យសាធារណៈរបស់រដ្ឋដែរ ឬទេ ?
ក្បាលដីដែលកំពុងស្នើសុំចុះបញ្ជី មានទំនាស់ ដែរឬទេ ? ។

បន្ទាប់ពីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ហើយ មេឃុំឬចៅសង្កាត់នោះ ត្រូវចារលើពាក្យស្នើសុំ រួចផ្ញើបែបបទបញ្ជូនពាក្យស្នើសុំទាំងនោះមករដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ។

រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវត្រួតពិនិត្យពាក្យស្នើសុំចុះបញ្ជី ដោយផ្អែកលើគោលការណ៍ជំនាញ និងច្បាប់ ៖

- ក្នុងករណីពិនិត្យឃើញថា ពាក្យស្នើសុំមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវកត់ត្រាពាក្យស្នើសុំទាំងនោះចូលក្នុង សៀវភៅទទួលពាក្យចុះលេខ រួចចារលើពាក្យនោះ កំណត់កាលបរិច្ឆេទ និងទីកន្លែងដែលត្រូវចុះអនុវត្តកំណត់ព្រំដី វាស់វែង និងវិនិច្ឆ័យ ហើយប្រគល់ពាក្យមួយច្បាប់ជូនអ្នកដាក់ពាក្យវិញ ។ ប្រសិនបើមានក្បាលដីច្រើនមានទីតាំងស្ថិតនៅជាប់គ្នា ឬជិតគ្នាក្នុងឃុំ សង្កាត់ជាមួយគ្នា ហើយទទួលបានការយល់ព្រមឱ្យអនុវត្តនីតិវិធីចុះបញ្ជី និងកំណត់កាលបរិច្ឆេទចុះអនុវត្តការងារវាលថ្ងៃជាមួយគ្នា ពាក្យស្នើសុំចុះបញ្ជីក្បាលដីទាំងនោះ អាចត្រូវបានប្រមូលផ្តុំទៅតាមលទ្ធភាពដែលក្រុមការងារវាល អាចអនុវត្តបានក្នុងមួយថ្ងៃ ដើម្បីបង្កើតបញ្ជីឈ្មោះអ្នកស្នើសុំចុះបញ្ជីដី និងធ្វើសេចក្តីជូនដំណឹងតែមួយដាក់ជូនអភិបាលស្រុក ខណ្ឌ ចុះហត្ថលេខាក្នុងរយៈពេលមិនលើសពី ៣ ថ្ងៃបន្ទាប់ពីរដ្ឋបាលសុរិយោដីស្រុក ខណ្ឌ លើកសំណើ ដើម្បីកំណត់ជាផ្លូវការនូវកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវអនុវត្ត ។ សេចក្តីជូនដំណឹងនេះ ត្រូវប្រគល់ជូនអ្នកដាក់ពាក្យស្នើសុំ និងបិទផ្សាយឱ្យបានយ៉ាងតិច ១៤ (ដប់បួន) ថ្ងៃ មុន កាលបរិច្ឆេទនៃការចុះកំណត់ព្រំដី នៅសាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ និងនៅ កន្លែងដែលងាយមើលឃើញក្នុងភូមិដែលក្បាលដី ស្នើសុំចុះបញ្ជីនោះស្ថិតនៅ ។
- ក្នុងករណីពិនិត្យឃើញថា កាលបរិច្ឆេទនៃការចូលកាន់កាប់ដីរដ្ឋ កើតឡើងក្រោយថ្ងៃ ៣០ សីហា ២០០១ រដ្ឋបាលសុរិយោដីស្រុក ខណ្ឌ ត្រូវចារលើពាក្យស្នើសុំឱ្យបានច្បាស់អំពី ភាពខុសច្បាប់នៃការចូលកាន់កាប់ដី ហើយប្រគល់ពាក្យនោះទៅសាមីអ្នកស្នើសុំវិញ ។